**រាជបណ្ឌិត្យសភាកម្ពុជា**
**វិទ្យាស្ថានមនុសាស្ត្រនិងវិទ្យាសាស្ត្រសង្គម**

# ក្រមសីលធម៌របស់មន្ត្រីសាធារណៈ

បណ្ឌិត **ហែម ឡាច**

*ខែមិថុនា ឆ្នាំ២០១៩*

# ក្រមសីលធម៌របស់មន្ត្រីសាធារណៈ

បណ្ឌិត **ហែម ឡាច**
មន្ត្រីស្រាវជ្រាវវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម
នៃរាជបណ្ឌិត្យសភាកម្ពុជា

## សេចក្តីផ្តើម

នៅក្នុងសង្គមជាតិនីមួយៗ មនុស្សម្នាក់ៗត្រូវទទួលបាននូវឱកាសមួយដើម្បីអភិវឌ្ឍថាមពលគំនិតប្រាជ្ញា ថាមពលផ្លូវចិត្ត ផ្លូវអារម្មណ៍តាមរយៈការសិក្សានិងសមាធិ។ ការរីកចម្រើននៃបច្ចេកវិទ្យាឬវិទ្យាសាស្ត្រនៃពិភពលោកជាចាំបាច់ត្រូវស្វែងយល់ពីទស្សនៈជាមូលដ្ឋានរបស់វា។ គោលការណ៍សីលធម៌ ឬ ក្រមសីលធម៌ ត្រូវបានគេទទួលស្គាល់ថាជាវិទ្យាសាស្ត្រនៃអំពើល្អ។ វិជ្ជានិងសីលធម៌ត្រូវដើរទន្ទឹមគ្នា។ ក្រមសីលធម៌ គឺជាលក្ខណសម្បត្តិខ្ពស់បំផុតរបស់មនុស្ស។ វាជាម៉ែត្រសម្រាប់វាស់ស្ទង់នូវអំពើល្អនិងអំពើអាក្រក់របស់មនុស្ស។ វាបានកំណត់ករណីយកិច្ចរបស់យើង ហើយចង្អុលបង្ហាញប្រាប់យើងថាអ្វីដែលយើងត្រូវធ្វើនិងអ្វីដែលយើងមិនត្រូវធ្វើ។ ក្រមសីលធម៌បានកំណត់អំពីដែនសមត្ថកិច្ចរបស់អ្នកប្រតិបត្តិការងារទៅតាមវិស័យនីមួយៗដើម្បីរក្សាគុណតម្លៃរបស់បុគ្គលក៏ដូចជាស្ថាប័នទាំងមូល។

## ១- និយមន័យនៃក្រមសីលធម៌មន្ត្រីសាធារណៈ

ក្រមសីលធម៌ + មន្ត្រីសាធារណៈ > ក្រមសីលធម៌មន្ត្រីសាធារណៈ

### ១.១- ក្រមសីលធម៌

ក្រមសីលធម៌ < ក្រម + សីលធម៌

-ក្រម ( សំ ) : - លំដាប់ ក្បួន បែប ពួក ប៉ែក បណ្តុំ ចង្កោម ...

ឧទាហរណ៍ : ក្រមព្រហ្មទណ្ឌ ក្រមរដ្ឋប្បវេណី ...

-សីលធម៌ < សីល + ធម៌

ប្រក្រតី សភាវៈ / ការទ្រទ្រង់

ក្រមសីលធម៌

ក- សំដៅដល់សភាវៈ ឬ ការទ្រទ្រង់នូវប្រក្រតីភាពទៅតាមលំដាប់លំដោយនៃវិស័យនីមួយៗ។

ខ- សំដៅដល់បណ្តុំនៃសីលធម៌ដែលជាវិធាន ឬ វិន័យចង្អុលបង្ហាញឱ្យប្រតិបត្តិដើម្បីទទួលបាននូវកិត្តិយសនិងសេចក្តីថ្លៃថ្នូរ

### ១.២- មន្ត្រីសាធារណៈ

មន្ត្រីសាធារណៈ < មន្ត្រី + សាធារណៈ

-មន្ត្រី (សំ.) = មន្តី (បា.) = អ្នកមានមន្ត អ្នកមានភាពទាក់ទាញ អ្នកមានគំនិត អ្នកមានសេចក្តីដឹងការងាររាក់ជ្រៅ អ្នកប្រឹក្សាដែនដី...

-សាធារណៈ (សំ. បា.) = ដែលទូទៅ ដែលមិនចំពោះ ដែលប្រើបានទាំងអស់គ្នា

មន្ត្រីសាធារណៈ  សំដៅដល់មន្ត្រីដែលបម្រើការងារក្នុងរដ្ឋបាលសាធារណៈ( ស្ថាប័នរដ្ឋ ) ដែលផ្តល់សេវាដល់ប្រជាពលរដ្ឋដោយមិនចំពោះ។

### ១.៣- ក្រមសីលធម៌មន្ត្រីសាធារណៈ

**ក្រមសីលធម៌មន្ត្រីសាធារណៈ** គឺសំដៅដល់បណ្តុំនៃវិន័យ ឬ វិធានសីលធម៌ចង្អុលបង្ហាញឱ្យមន្ត្រីសាធារណៈអនុវត្តដើម្បីរក្សាបាននូវគុណតម្លៃ កិត្តិយស និង សេចក្តីថ្លៃថ្នូររបស់ខ្លួន។ ក្រមសីលធម៌បានបញ្ញត្តិ និង អនុញ្ញាតដល់មន្ត្រីសាធារណៈគួរប្រតិបត្តិ និង មិនគួរប្រតិបត្តិទៅតាម ទីកន្លែង ពេលវេលា ឋានានុក្រម។

## ២- សមាសធាតុនៃក្រមសីលធម៌មន្ត្រីសាធារណៈ

មន្ត្រីសាធារណៈគ្រប់រូបត្រូវតែគោរពនិងរក្សាឱ្យបានខ្ជាប់ខ្ជួននូវក្រមសីលធម៌ទាំង១០ ប្រការដូចខាងក្រោម ៖

- ការគោរពពេលវេលា
- ការគោរពឋានានុក្រម
-ការគោរពការចាត់តាំង
- ការគោរពវិន័យការងារ
- ការរក្សាសីលធម៌
- ការរក្សាសុចរិតភាព
- ការរក្សាភក្តីភាព
-ការរក្សាឥស្សរភាព
- រក្សាអព្យាក្រឹតភាព
-ការរក្សាអាថ៌ភាព

### ២.១- ការគោរពពេលវេលា

យោងតាមស្មារតីនៃអនុក្រឹត្យលេខ...... ចុះថ្ងៃទី... ខែ...... ឆ្នាំ...... បានកំណត់អំពីពេលវេលាបំពេញការងាររបស់មន្ត្រីរាជការគឺ ៖

- ពេលព្រឹក : ចូលម៉ោង ៧ : ០០ - ១១ : ៣០
- ពេលរសៀល : ចូលម៉ោង ២ : ០០ - ៥ : ៣០

ក្នុងមួយថ្ងៃធ្វើការ៨ម៉ោងក្នុងមួយសប្តាហ៍ បំពេញការងាររយៈពេល៥ថ្ងៃ គឺពីថ្ងៃចន្ទដល់ថ្ងៃសុក្រ។

### ២.២- ការគោរពឋានានុក្រម

ឋានានុក្រម គឺជាលំដាប់នៃឋានៈដែលរៀបចំឡើងតាមអង្គភាព ក្រសួងស្ថាប័ន។ បញ្ហាឋានានុក្រម ជាបញ្ហាស្មុគស្មាញមួយដែលមន្ត្រីសាធារណៈតែងតែប្រុងប្រយត្នជាទីបំផុត ព្រោះវាពាក់ព័ន្ធទៅនឹងកិត្តិយស មុខមាត់របស់ខ្លួននិងរបស់អ្នកដទៃ។

**ក- ឋានានុក្រមការទូត**

- ព្រះមហាក្សត្រ ឬ ព្រះចៅអធិរាជ
- ប្រមុខរដ្ឋ ឬ ប្រធានាធិបតី
- ប្រធានព្រឹទ្ធសភា

- ប្រធានរដ្ឋសភា
- នាយករដ្ឋមន្ត្រី
- រដ្ឋមន្ត្រីការបរទេស
- រដ្ឋមន្ត្រីការពារជាតិ

**ខ- ឋានានុក្រមអង្គទូត**

- ឯកអគ្គរាជទូត
- បេសិតជនពិសេស
- ភារធារីមានលិខិត
- ភារធារីស្តីទី

**គ- ឋានានុក្រមផ្ទៃក្នុងស្ថានទូត**

- ឯកអគ្គរាជទូត
- រដ្ឋមន្ត្រីពេញសមត្ថភាព
- អគ្គរាជទូត
- អគ្គទីប្រឹក្សា
- ទីប្រឹក្សា
- ទីប្រឹក្សាយោធា...
- អគ្គកុងស៊ុល
- លេខាធិការ
- អនុពន្ធស្ថាបទូត
- កុងស៊ុល / កុងស៊ុលកិត្តិយស

**ឃ- ឋានានុក្រមក្នុងព្រះរាជាណាចក្រកម្ពុជា**

-ឋានានុក្រមព្រះពុទ្ធសាសនា ( មហានិកាយ ធម្មយុត្តិកនិកាយ )
-ឋានានុក្រមខត្តិយវង្ស ( ខ្សែរាជវង្ស )
-ឋានានុក្រមនីតិប្បញ្ញត្តិ ( ព្រឹទ្ធសភា / រដ្ឋសភា )
-ឋានានុក្រមនីតិប្បដិបត្តិ ( មន្ត្រីនយោបាយ / មន្ត្រីរាជការ )
-ឋានានុក្រមតុលាការ ( តុលាការជាន់ខ្ពស់ / តុលាការជាន់ទាប )
-ឋានានុក្រមកងយោធពលខេមរភូមិន្ទ និង នគរបាលជាតិ
-ឋានានុក្រមចម្រុះ ( នីតិប្បញ្ញត្តិ នីតិប្បដិបត្តិ យុត្តាធិការ )

រដ្ឋបាលសាធារណៈ គឺជារដ្ឋបាលដែលមានឋានានុក្រមជាក់លាក់ ( ថ្នាក់លើ ថ្នាក់ក្រោម ) ថ្នាក់លើត្រូវប្រកាន់យកនូវ " បោរីភាព " ចំពោះថ្នាក់ក្រោមហើយថ្នាក់ក្រោមត្រូវសម្តែងនូវអាកប្បកិរិយាសមរម្យជាកាយវិការ " គោរព " ចំពោះថ្នាក់លើ។ ប្រការនេះ បើមិនមានតម្រូវដោយច្បាប់ក៏ជាបែបបទសុជីវធម៌ក្នុងការរស់នៅក៏ដូចជាក្នុងទំនាក់ទំនងជាទូទៅផងដែរ។

## ២.៣- ការគោរពតាមការចាត់តាំង

មន្ត្រីរាជការគ្រប់រូប ត្រូវប្រតិបត្តិដោយស្មារតីទទួលខុសត្រូវខ្ពស់ចំពោះការងារនិងមានគំនិតច្នៃប្រឌិត

ដើម្បីឱ្យការងារីកចម្រើននិងប្រកបដោយគុណភាព។ មន្ត្រីរាជការមិនមែនធ្វើការងារឱ្យគ្រាន់តែរួចពីដៃ ឬ រួចខ្លួននោះទេ។ មាត្រា៣៣ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលបានចែងថា ៖ " អ្នករាជការត្រូវទទួលខុសត្រូវចំពោះមុខថ្នាក់លើអំពីកិច្ចការរបស់ខ្លួននិងអំពើដែលអាចធ្វើឱ្យប៉ះពាល់ទៅលើសេចក្តីថ្លៃថ្នូរនិងកិត្តិយសរបស់ខ្លួន។ អ្នករាជការក្នុងក្របខណ្ឌទាំងអស់ត្រូវគោរពបញ្ជារបស់ថ្នាក់លើដែលបានចាត់ឱ្យទៅបម្រើការងារទោះបីតំបន់ណាក៏ដោយទាំងក្នុងនិងក្រៅប្រទេស"។ នេះសបញ្ជាក់ឱ្យឃើញថា មន្ត្រីរាជការទាំងអស់ត្រូវគោរពតាមការចាត់តាំង ឬ ការបញ្ជាពីថ្នាក់លើរបស់ខ្លួនដោយមិនអាចប្រឆាំងជំទាស់ ឬ ប្រកែកបានឡើយ។ ប៉ុន្តែអ្នករាជការអាចមានសិទ្ធិលើកជាសំណើ ឬ ផ្តល់ជាយោបល់ទៅថ្នាក់លើរបស់ខ្លួនក្នុងករណីដែលខ្លួនយល់ឃើញថា យោបល់ ឬ គំនិតរបស់ខ្លួនល្អប្រសើរមានសារប្រយោជន៍ដល់អង្គភាព (ថ្នាក់លើទទួលយកយោបល់របស់ខ្លួន ឬមិនទទួលយកគឺជាសិទ្ធិរបស់ថ្នាក់លើ)។ អ្នករាជការគ្មានសិទ្ធិបដិសេធមិនអនុវត្តតាមបទបញ្ជារបស់ថ្នាក់លើទេ លើកលែងតែបទបញ្ជានោះជាទង្វើខុសច្បាប់។

រាល់ការចាត់តាំង ការដាក់ចេញនូវបទបញ្ជាត្រូវតែប្រកាន់ខ្ជាប់ខ្ជួននិងអនុវត្តឱ្យបានត្រឹមត្រូវទៅតាមនីតិវិធីនិង គោលការណ៍ដែលកំណត់ដោយច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងៗ។

**២.៤- ការគោរពវិន័យការងារ**

មន្ត្រីរាជការទាំងអស់ត្រូវគោរពវិន័យការងារស្របតាមជំពូកទី៥នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល និងបទដ្ឋានគតិយុត្តផ្សេងៗទៀត។

ត្រូវហាមឃាត់ដាច់ខាតដល់អ្នករាជការនូវប្រការដូចខាងក្រោម ៖

-យកម៉ោងរដ្ឋបាលទៅប្រកបមុខរបរផ្ទាល់ខ្លួន។

-យកអំណាចនិងឥទ្ធិពលនៅក្នុងមុខងាររបស់ខ្លួនទៅប្រើប្រាស់ដើម្បីទាញយកផលប្រយោជន៍ឬសំឡុតគំរាមកំហែងបំពានសិទ្ធិរបស់ពលរដ្ឋ។

-ប្រកបមុខរបរដែលនាំឱ្យប៉ះពាល់ដល់កិត្តិយស និងសេចក្តីថ្លៃថ្នូរនៃអ្នករាជការ។

-ចូលជាសមាជិកក្រុមប្រឹក្សាភិបាល ឬ គ្រប់គ្រងក្រុមហ៊ុនឯកជនដោយផ្ទាល់ ឬដោយប្រយោល។

-បោះពុម្ពផ្សាយ ឬ ធ្វើការផ្សព្វផ្សាយព័ត៌មានដែលមានការពាក់ព័ន្ធនៅក្នុងមុខងាររបស់ក្រសួងដោយពុំមានការអនុញ្ញាតពីប្រធានស្ថាប័នដែលសាមីខ្លួននៅក្រោមឱវាទ។

-ប្រកបមុខរបរបន្ថែមត្រួតលើមុខងាររបស់ខ្លួនជាអ្នករាជការក្នុងករណីដែលលក្ខន្តិកៈដោយឡែកនៃអង្គនីមួយៗហាមឃាត់។

ប្រសិនបើអ្នករាជការប្រព្រឹត្តបំពាន់និងចំណុចដូចបានរៀបរាប់ខាងលើត្រូវទទួលទណ្ឌកម្មផ្នែកវិន័យដូចមានចែងក្នុងមាត្រា៤០នៃច្បាប់សហលក្ខន្តិក ( ដោយមិនទាន់គិតការចោទប្រកាន់ជាបទអាជ្ញាដែលអាចកើតមានឡើង )។

**២.៥- ការរក្សាសីល ( សីលធម៌ )**

សីល ឬ សីលធម៌ គឺជាមូលដ្ឋានសារវន្តនៃក្រមសីលធម៌ដែលមន្ត្រីរាជការគ្រប់រូបត្រូវតែរក្សាឱ្យបានខ្ជាប់ខ្ជួនគ្រប់ពេលវេលាជានិច្ចនិរន្តរ។ សីលធម៌ជាជំបូលដែលផ្តល់នូវម្លប់ដ៏ត្រជាក់ត្រជុំសុខដុមរមនាក្នុងការងារក៏ដូចជាក្នុងជីវិត។ លោកអារីស្តូត(Aristote) ចាត់ទុកសីលធម៌ជាទម្លាប់ក្នុងការប្រព្រឹត្តដោយគាត់យល់ឃើញថា"អំពើដ៏ប្រុងប្រយត្ន គឺជាសីលធម៌"។ ចំណែក "អំពើជ្រុលហួសហេតុ គឺជាអសីលធម៌ ឬអំពើអាក្រក់"។ មនុស្សមានសីលធម៌ប្រកាន់យកផ្លូវកណ្តាលក្នុងចរិយាផ្ទាល់ខ្លួននិងសង្គម។ មនុស្សមានសីលធម៌ មិនជ្រុល

និយម មើលឃើញវែងឆ្ងាយ ចេះស្គាល់ប្រមាណខ្លួនឯងនិងអ្នកដទៃ ស្គាល់កាលៈទេសៈហើយប្រកាន់ចរិយាសមរម្យចំពោះអ្នកដទៃជុំវិញខ្លួន។

ចំណែកគោលការណ៍សីលធម៌របស់ព្រះពុទ្ធសមណគោតម ក្នុងបញ្ចសីល ឬ និច្ចសីលគឺៈ

- វៀរចាកការសម្លាប់ជីវិតមនុស្សសត្វផងទាំងពួង
- វៀរចាកការកាន់យកទ្រព្យសម្បត្តិរបស់អ្នកដទៃ
- វៀរចាកការរួមបវេណី គឺប្រព្រឹត្តផ្លូវភេទជាមួយប្រពន្ធ កូនរបស់អ្នកដទៃ
- វៀរចាកការនិយាយពាក្យមិនពិត
- វៀរចាកការផឹកទឹកស្រវឹងដែលជាហេតុនាំឱ្យកើតសេចក្ដីប្រមាថផ្សេងៗ។

លើសពីនេះលោកក៏ចង្អុលបង្ហាញទៅលើព្រហ្មវិហារធម៌ និង អរិយសច្ចធម៌ ពិសេសផ្ដោតទៅលើអដ្ឋង្គិកមគ្គ ឬមាគ៌ាទាំង៨ ( សម្មាទិដ្ឋិ សម្មាសង្កប្បៈ សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ សម្មាវាយាម សម្មាសតិ និងសម្មាសមាធិ )។

## ២.៦- ការរក្សានូវសុចរិតភាព

មន្ត្រីរាជការគ្រប់រូបត្រូវប្រព្រឹត្តឱ្យបានល្អត្រឹមត្រូវតាមគន្លងធម៌ស្របនឹងច្បាប់ទម្លាប់នៃសង្គមជាតិដើម្បីសេចក្ដីសុខក្សេមក្សាន្តរបស់ខ្លួននិងប្រជាពលរដ្ឋទូទៅទាំងប្រទេស។ អ្នកដែលបានប្រកាន់ខ្ជាប់ខ្លួននូវសុចរិតភាពនឹងក្លាយទៅជាមនុស្សដែលទទួលបាននូវជំនឿទុកចិត្តពីអ្នកផងទាំងពួង។ ដើម្បីរក្សាបាននូវសុចរិតភាព មន្ត្រីត្រូវប្រតិបត្តិនូវ "កុសលកម្ម ឬកម្មបទ១០ប្រការ (កាយកម្ម៣ វចីកម្ម៤ មនោកម្ម៣ )"។

គុណតម្លៃនៃសុចរិតភាពនាំឱ្យមន្ត្រីរាជការ ៖

- រស់ក្នុងសុភមង្គលនិងសេចក្ដីថ្លៃថ្នូរ
- មានការគោរពស្រលាញ់ពីមនុស្សជុំវិញខ្លួន
- សង្គមជាតិមានសន្តិភាពនិងការអភិវឌ្ឍ

## ២.៧- ការរក្សានូវភក្ដីភាព

អ្នករាជការទាំងអស់ត្រូវតែមានភក្ដីភាពចំពោះជាតិ សាសនា និងព្រះមហាក្សត្ររបស់ខ្លួន។ មន្ត្រីរាជការគឺជាអ្នកមានគំនិត អ្នកមានសេចក្ដីដឹងការរាក់ជ្រៅ អ្នកប្រឹក្សាការផែនដីដែលត្រូវបានរដ្ឋប្រគល់សេចក្ដីទុកចិត្តចាត់តាំងឱ្យបំពេញភារកិច្ចដែលជាអាយុជីវិតប្រទេសជាតិជាទីទំនុកទុកចិត្តបំផុតរបស់រដ្ឋ។ ដូច្នេះមន្ត្រីត្រូវតែមានភក្ដីភាពជានិច្ចចំពោះប្រទេសជាតិមាតុភូមិ ចំពោះមាគ៌ានយោបាយរបស់រដ្ឋ ចំពោះឧត្ដមប្រយោជន៍របស់ជាតិ និងចំពោះអ្នកដែលបានចាត់តាំង តែងតាំង ឬ ប្រគល់ភារកិច្ចឱ្យខ្លួនបំពេញការងារ។

អ្នកដឹកនាំអង្គភាព ត្រូវតែមានភក្ដីចំពោះក្រសួង ចំពោះថ្នាក់ដឹកនាំក្រសួង។ ចំណែកអ្នកដឹកនាំក្រសួងត្រូវមានភក្ដីភាពចំពោះរាជរដ្ឋាភិបាល ចំពោះគោលនយោបាយរបស់រដ្ឋាភិបាល។ ឯអ្នករាជការដទៃទៀត ត្រូវតែមានភក្ដីភាពចំពោះថ្នាក់លើដែលខ្លួនស្ថិតនៅក្រោមឱវាទជាបន្តបន្ទាប់។

## ២.៨- ការរក្សាឥស្សរភាព

អ្នករាជការគ្រប់រូបត្រូវទទួលខុសត្រូវចំពោះមុខថ្នាក់លើអំពីកិច្ចការរបស់ខ្លួន និងអំពើទាំងឡាយណាដែលអាចធ្វើឱ្យប៉ះពាល់សេចក្ដីថ្លៃថ្នូរនិងកិត្តិយសរបស់ខ្លួន (មាត្រា៣៣នៃច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល) ដោយហាមឃាត់ដាច់ខាតមិនឱ្យអ្នករាជការប្រកបមុខរបរណាដែលធ្វើឱ្យប៉ះពាល់ដល់កិត្តិយស និងសេចក្ដីថ្លៃថ្នូរនៃអ្នករាជការ (មាត្រា៣៥)។

ទោះស្ថិតក្នុងកាលៈទេសៈណាក៏ដោយអ្នករាជការមិនត្រូវធ្វើអ្វីមួយដែលនាំឱ្យខូច ឬ អាប់ឱនដល់កិត្តិយស និង សេចក្តីថ្លៃថ្នូររបស់ខ្លួនឡើយ ព្រោះថាបើអ្នករាជការគ្មានកិត្តិយស ឬ គ្មានសេចក្តីថ្លៃថ្នូរនោះវាជារូបភាពមិនល្អចំពោះរដ្ឋបាលសាធារណៈឡើយ។ សេចក្តីថ្លៃថ្នូរ និង កិត្តិយសដែលជាឥស្សរភាពស្តែងចេញពីការប្រព្រឹត្តត្រឹមត្រូវតាមក្រមសីលធម៌តាមគោលការកំណត់របស់រដ្ឋ មិនប្រពឹត្តអំពើអបាយមុខ មានភាពទៀងត្រង់ សុចរិត យុត្តិធម៌ មិនទទួលសំណូកសូកប៉ាន់ មិនចូលរួមជាមួយអតិថិជនលួចបន្លំពន្ធដារសារអាករ។ល។

កិត្តិយស និង សេចក្តីថ្លៃថ្នូរតម្រូវលើគ្រប់សកម្មភាពនិងគ្រប់កាលៈទេសៈទាំងអស់រួមទាំងសំដីសំដៅ អាកប្បកិរិយា ឥរិយាបថ ការស្លៀកពាក់តុបតែងខ្លួនប្រាណប្រចាំថ្ងៃផងដែរ។ ការប្រព្រឹត្តអំពើមិនសមរម្យប្រកបមុខរបរដែលពុទ្ធចក្ក និង អាណាចក្កហាមឃាត់ សុទ្ធតែជាសកម្មភាពដែលអ្នករាជការគ្រប់រូបត្រូវចៀសវាង ព្រោះនាំឱ្យសាធារណជនវាយតម្លៃមិនល្អដល់មន្ត្រីរាជការនោះផង និង ដល់រដ្ឋបាលសាធារណៈតំណាងអំណាចសាធារណៈរបស់រដ្ឋផងដែរ។

អ្នករាជការទាំងអស់ ត្រូវតែចៀសវាងឱ្យខាងតែបាននូវការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌផ្សេងៗ ព្រោះថាចំពោះមុខភ្នែកសាធារណជនអ្នករាជការតំណាងឱ្យប្រយោជន៍រួមតំណាង អំណាចសាធារណៈ តំណាងការគោរពច្បាប់និងតំណាងឱ្យនីតិរដ្ឋទាំងមូល។ ការប្រព្រឹត្តមិនល្អក្នុងជីវភាពរស់នៅជាលក្ខណៈឯកជនក្តី ការប្រព្រឹត្តល្មើសនឹងច្បាប់រដ្ឋនានាក្តីគឺសុទ្ធតែបង្កជារូបភាពមិនល្អដល់សេចក្តីថ្លៃថ្នូររបស់អ្នករាជការនិងដល់ជំនឿទុកចិត្តរបស់សាធារណជនលើសកម្មភាពដឹកនាំ និងលើគោលនយោបាយរបស់រាជរដ្ឋាភិបាលទាំងមូលទៀតផង។

## ២.៩- ការរក្សាអព្យាក្រឹតភាព

មន្ត្រីរាជការត្រូវមានអព្យាក្រឹតភាពក្នុងសកម្មភាពការងារ និង ហាមឃាត់ដាច់ខាតនូវការប្រើប្រាស់មុខងាររបស់ខ្លួន និង សម្ភារៈរបស់រដ្ឋដើម្បីបម្រើសកម្មភាពនយោបាយដូចខាងក្រោម៖

- ធ្វើការដើម្បីផលប្រយោជន៍ដល់បេក្ខជននយោបាយ ឬ ប្រឆាំងនឹងបេក្ខជននយោបាយណាមួយ ឡើយ។
- ធ្វើការដើម្បីផលប្រយោជន៍គណបក្សនយោបាយ ឬ ប្រឆាំងគណបក្សនយោបាយណាមួយឡើយ។

ការណ៍ដែលអ្នករាជការសាធារណៈប្រព្រឹត្តផ្ទុយនឹងចំណុចនេះ ត្រូវចាត់ទុកជាកំហុស និង ការផ្តាំផ្តងក្នុងវិជ្ជាជីវៈរបស់អ្នករាជការ (មាត្រា៣៧)។

ក្នុងការបំពេញការងារក៏ដូចជាការបម្រើអតិថិជនជាប្រជាពលរដ្ឋ (អ្នកទទួលសេវាពីរដ្ឋ) អ្នករាជការទាំងអស់ត្រូវប្រកាន់ខ្ជាប់នូវអព្យាក្រឹតភាពមិនលម្អៀង មិនអគតិភាព។ អនាព្យាក្រឹត(ភាពមិនអព្យាក្រឹត)នាំមកនូវគ្រោះថ្នាក់ធ្ងន់ដល់អាយុជីវិត និង អនាគតអ្នកទទួលសេវាពីរដ្ឋ។ មន្ត្រីរាជការ គឺជាអ្នកបម្រើរដ្ឋ បម្រើប្រជាពលរដ្ឋ បម្រើផលប្រយោជន៍សាធារណៈ ប្រយោជន៍រួម មិនមែនប្រយោជន៍បុគ្គល ឬ ប្រយោជន៍ក្រុមបក្សពួកណាមួយឡើយ។ ច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលក៏បានហាមប្រាមដាច់ខាតផងដែរដល់អ្នករាជការក្នុងពេលបំពេញការងារមិនឱ្យយកអំណាចនៅក្នុងមុខងាររបស់ខ្លួនទៅប្រើដើម្បីទាញយកផលប្រយោជន៍អ្វីមួយ ឬ ដើម្បីសំឡុតគំរាមកំហែងបំពានសិទ្ធិរបស់ប្រជាពលរដ្ឋ (មាត្រា៣៥លក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីរាជការ) ការប្រើប្រាស់មុខងារ សម្ភារៈ និងបុគ្គលិករដ្ឋដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ជាពិសេសដើម្បីសកម្មភាពនយោបាយ គឺជាប្រការដែលផ្ទុយនឹងគោលការអព្យាក្រឹតភាពនៃរដ្ឋបាលសាធារណៈហើយក៏ត្រូវហាមប្រាមជាដាច់ខាតដែរ(មាត្រា៣៧លក្ខន្តិកៈ ដោយឡែកនៃក្របខណ្ឌមន្ត្រីរាជការ)។ ទោះបីមាត្រា៣៧បានចែងបែបនេះក៏ដោយក៏មិនមែនមានន័យថា : មិនឱ្យអ្នករាជការទៅចូលរួមគណបក្សនយោបាយ ឬ មិនឱ្យអ្នករាជការទៅគាំទ្រគណបក្សនយោ បាយណានោះទេ

គឺអ្នករាជការមានសិទ្ធិចូលរួមក្នុងគណបក្សនយោបាយ ឬ គាំទ្រគណបក្សណាមួយដែលខ្លួនពេញចិត្ត។ ប៉ុន្តែហាមមិនឱ្យអ្នករាជការនោះយកតួនាទី មុខងាររបស់ខ្លួនជាអ្នករាជការទៅបម្រើនយោបាយ ឬ យកសម្ភារៈ មធ្យោបាយធ្វើដំណើរ រថយន្ត សម្លៀកបំពាក់ ដែលមានឯកសណ្ឋានជាអ្នករាជការទៅបម្រើគណបក្សនយោបាយ ឬ ទៅឃោសនាឱ្យគណបក្សនយោបាយ ( ទំព័រ៨០ : នីតិមុខងារសាធារណៈ : តន យឿន )។

ក្នុងច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការមាត្រា៣៦ : អនុញ្ញាតឱ្យមន្ត្រីទាំងឡាយ មានសិទ្ធិចូលរួមក្នុងការគ្រប់គ្រងសមាគមស្របច្បាប់ដោយសេរី។

**១០- ការរក្សាអាថ៌កំបាំង ( ភាពអាថ៌កំបាំង/ការសម្ងាត់ )**

អ្នករាជការមិនត្រូវធ្វើឱ្យខូច ឬ អាប់ឱនកិត្យានុភាពរបស់ក្រសួងស្ថាប័នទេ។ ពោលគឺ អ្នករាជការត្រូវ "ចេះលាក់ការណ៍"។ គោរពលាក់ការណ៍ការងារ គឺរក្សានូវពាក្យសម្តីដែលនិយាយចេញទៅ ឬ សរសេរចេញទៅត្រូវមានភាពប្រុងប្រយ័ត្នដោយមិននិយាយ ឬសរសេរនូវអ្វីដែលធ្វើឱ្យមានការប៉ះពាល់ដល់កិត្តិយសកិត្យានុភាពរបស់អង្គភាព ក្រសួង ស្ថាប័ន ឬ សមត្ថកិច្ចថ្នាក់ដឹកនាំរបស់ខ្លួនឡើយ។ លាក់ការណ៍ ឬ ការរក្សាការណ៍សម្ងាត់ រក្សាការប្រុងប្រយ័ត្នក្នុងវិជ្ជាជីវៈនៃអ្នករាជការ គឺដាច់ខាតអ្នករាជការមិនត្រូវបង្ហាញអាថ៌កំបាំងផ្ទៃក្នុងការងារឱ្យបែកធ្លាយចេញទៅក្រៅនូវរាល់ឯកសារ ព័ត៌មាន ឬ ព្រឹត្តិហេតុផ្សេងៗ ដែលខ្លួនបានដឹងបានឮនៅក្នុងការងារ ឬ នៅក្នុងពេលបំពេញការងារ បើសិនជាគ្មានការអនុញ្ញាតពីថ្នាក់លើរបស់ខ្លួន ឬ ក្រៅពីសមត្ថកិច្ចរបស់ខ្លួន ឬ គ្មានការកំណត់ដោយច្បាប់។

ត្រូវហាមឃាត់ជាដាច់ខាតដល់អ្នករាជការនូវការបោះពុម្ពផ្សាយ ឬ ធ្វើការផ្សព្វផ្សាយព័ត៌មានដែលមានការពាក់ព័ន្ធនៅក្នុងមុខងារក្រសួងដោយពុំមានការអនុញ្ញាតជាមុនពីប្រធានស្ថាប័នដែលសាមីខ្លួនស្ថិតនៅក្រោមឱវាទ។ការសម្ងាត់វិជ្ជាជីវៈ ហាក់ដូចជាមានលក្ខណៈផ្ទុយគ្នានឹងគោលការណ៍ "តម្លាភាព" នៃគោលការណ៍ប្រជាធិបតេយ្យនិងសិទ្ធិរបស់ប្រជាពលរដ្ឋដូចដែលមានចែងក្នុងមាត្រា៣៥នៃរដ្ឋធម្មនុញ្ញៈ "សេចក្តីស្នើទាំងឡាយរបស់ប្រជាពលរដ្ឋត្រូវបានទទួលការពិនិត្យ និងដោះស្រាយយ៉ាងហ្មត់ចត់ពីអង្គការរដ្ឋ"។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយក៏នៅមានការងារមួយចំនួនដែលរដ្ឋត្រូវ "រក្សាការណ៍សម្ងាត់" ជាពិសេសគឺព័ត៌មានដែលអាចធ្វើឱ្យមានការប៉ះពាល់ដល់សន្តិភាព សុវត្ថិភាព និងកិត្យានុភាពរបស់សង្គមជាតិ។ ការសម្ងាត់វិជ្ជាជីវៈមិនត្រឹមតែអនុវត្តចំពោះសាធារណជនប៉ុណ្ណោះទេ ប៉ុន្តែត្រូវអនុវត្តចំពោះសហសេវិក សហសេវិការបស់ខ្លួនដែលមិនមានភារកិច្ច ឬសមត្ថកិច្ចត្រូវដឹងនូវការងារនោះផងដែរ។

## ៣-ប្រភេទក្រមសីលធម៌តាមអង្គភាព ក្រសួង ស្ថាប័ន

- ក្រមសីលធម៌មន្ត្រីប្រតិបត្តិច្បាប់
- ក្រមសីលធម៌គ្រូបង្រៀន
- ក្រមសីលធម៌គ្រូពេទ្យ
- ក្រមសីលធម៌នៃមេធាវី
- ក្រមសីលធម៌ចៅក្រម
- ក្រមសីលធម៌អ្នកសារព័ត៌មាន
- ក្រមសីលធម៌សិល្បករ
- ក្រមសីលធម៌អ្នកសម្តែង
- ក្រមសីលធម៌អ្នកបង្កើតស្នាដៃ

**៣.១- ខ្លឹមសារសង្ខេបនៃក្រមសីលធម៌មន្ត្រីប្រតិបត្តិច្បាប់**

(មាន៨មាត្រា)

- ត្រូវគោរពនិងការពារសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ
- រក្សានិងលើកស្ទួយសិទ្ធិមនុស្សរបស់ជនគ្រប់រូប
- ការប្រើប្រាស់អាវុធត្រូវហាមឃាត់ (លើកលែងតែក្នុងករណីជនល្មើសតដៃ)
- រក្សាការសម្ងាត់វិជ្ជាជីវៈក្នុងពេលបំពេញភារកិច្ច
- មិនប្រព្រឹត្តការញុះញង់ ឬ ធ្វើទារុណកម្មដោយអមនុស្សធម៌
- ធានារក្សាសុខភាពជនទាំងឡាយដែលស្ថិតក្នុងការឃុំឃាំង
- មិនត្រូវប្រព្រឹត្តអំពើពុករលួយជាដាច់ខាត
- ត្រូវគោរពច្បាប់ និង មានវិន័យនៃអង្គភាព

**២- ខ្លឹមសារសង្ខេបនៃក្រមសីលធម៌គ្រូបង្រៀន**

(៣០មាត្រា អនុក្រឹត្យលេខ១២៦អនក្រ. បក. ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៨)

-គោរពពេលវេលា

-សម្លៀកបំពាក់សមរម្យ

-អាកប្បកិរិយាសមរម្យ

-វិធីសាស្ត្រល្អក្នុងការបង្រៀន

-ចំណេះដឹងទូលំទូលាយ

-យុត្តិធម៌មិនលម្អៀង

-មនសិការក្នុងការងារ

-ព្រហ្មវិហារធម៌

-មិនប្រព្រឹត្តអបាយមុខ

-គំរូល្អចំពោះមហាជន

**៣- ខ្លឹមសារសង្ខេបនៃក្រមសីលធម៌គ្រូពេទ្យ**

**(១១១មាត្រាអនុក្រឹត្យលេខ៦១អនក្រ.បក. ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៣)**

- គោរពជីវិត រាងកាយ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស
- សីលធម៌ សុចរិតភាព ភក្តីភាពក្នុងវិជ្ជាជីវៈ
- រក្សាការសម្ងាត់ក្នុងវិជ្ជាជីវៈ
- រូបភាពផ្សព្វផ្សាយបំផ្លើសខុសការណ៍ពិត(ហាមឃាត់)
- ចៀសវាងអំពើទាំងឡាយនាំឱ្យអាប់ឱនវិជ្ជាជីវៈ
- បញ្ជាក់ព័ត៌មានដោយស្មោះត្រង់
- ត្រូវឆ្លើយតបរាល់ការសុំព័ត៌មាន ឬ ការពន្យល់
- គោរពសិទ្ធិជ្រើសរើសរបស់អ្នកជំងឺ
- ហាមឃាត់ម៉ៅការដើម្បីប្រសិទ្ធភាពនៃការព្យាបាល
- មិនត្រូវលោភលន់ដោយប្រើឥទ្ធិពល

**៤- ខ្លឹមសារសង្ខេបនៃក្រមសីលធម៌មេធាវី**

**(ក្រុមប្រឹក្សាគណៈមេធាវី : ១៥ វិច្ឆិកា ១៩៩៥)**

- គោរពពាក្យសម្បថរបស់ខ្លួន
- ប្រកាន់ខ្ជាប់អាថ៌កំបាំងវិជ្ជាជីវៈ
- ហាមឃាត់មិនឱ្យធ្វើការទាក់ទាញភ្ញៀវមករកខ្លួនឡើយ
- គោរពសេរីភាពរបស់អតិថិជន
- ត្រូវផ្តល់ឯកសារដែលខ្លួនទទួលទុកដោយគ្មានសិទ្ធិកាន់ទុក
- គោរពតាមវិធាននៃនីតិវិធីនិងទម្លាប់នៃតុលាការ
- មិនត្រូវចូលរួមសកម្មភាពផ្ទុយពីច្បាប់ វិធាន បទបញ្ញាវិជ្ជាជីវៈ
- មានសិទ្ធិទទួល ឬ មិនទទួលកូនក្តី (លើកលែងប្រធានចាត់តាំង )
- មិនត្រូវធ្វើអ្វីដែលនាំឱ្យខាតប្រយោជន៍ដល់សហភាតា
- ទទួលខុសត្រូវចំពោះមុខសហភាតារបស់ខ្លួន

**៥- ខ្លឹមសារសង្ខេបនៃក្រមសីលធម៌ចៅក្រម**

**(ឧត្តមក្រុមប្រឹក្សានាំអង្គចៅក្រម : ២២ កុម្ភៈ ២០០៧)**

- ចៅក្រមត្រូវស្ថិតនៅជាអព្យាក្រឹតក្នុងសកម្មភាពនយោបាយ
- ចៅក្រមត្រូវឈរលើគោលការណ៍ឯករាជភាព (មិនទទួលរងឥទ្ធិពលផ្សេងៗ)
- ចៅក្រមត្រូវឈរលើគោលការណ៍អនាគតិ (ភាពមិនលម្អៀង)
- ចៅក្រមត្រូវឈរលើគោលការណ៍សុចរិតភាព (ទៀងត្រង់ / មិនប្រព្រឹត្តអំពើពុករលួយ)
- ចៅក្រមត្រូវឈរលើគោលការណ៍សេចក្តីថ្លៃថ្នូរ (រក្សាកិត្តិយសគ្រប់ឥរិយាបថ)
- ចៅក្រមត្រូវឈរលើគោលការណ៍វិរិយភាព (ឧស្សាហ៍ព្យាយាមដើម្បីសុក្រឹតភាព និង គុណភាពការងារ)

**៦- ខ្លឹមសារសង្ខេបនៃក្រមសីលធម៌អ្នកសារព័ត៌មាន**

**(ច្បាប់ស្តីពីរបបសារព័ត៌មាន : ១៨ កក្កដា ១៩៩៥)**

- សាធារណជនគោរពសច្ចធម៌និងសិទ្ធិយល់ដឹងនូវសច្ចធម៌របស់
- ត្រូវផ្សាយនូវដំណឹងទាំងឡាយដោយសុចរិតព្រមទាំងធ្វើអត្ថាធិប្បាយ ឬ រិះគន់ឱ្យត្រឹមត្រូវនិងសមស្របតាមគតិយុត្តិធម៌
- ត្រូវរាយការណ៍តែតាមហេតុការណ៍ដែលខ្លួនដឹងពីប្រភពដើមតែប៉ុណ្ណោះ។ អ្នកសារព័ត៌មានមិនត្រូវបំបាត់ចោលនូវព័ត៌មានសំខាន់ៗ ឬ កែបន្លំឯកសារផ្សេងៗឡើយ
- ប្រើវិធីសុចរិតត្រឹមត្រូវដើម្បីស្វែងរកដំណឹង រូបថត និងឯកសារផ្សេងៗ
- ត្រូវធ្វើការកែតម្រូវនូវព័ត៌មានណាដែលចេញផ្សាយរួចហើយៗមានលក្ខណៈមិនជាក់លាក់និងនាំឱ្យមានការយល់ច្រឡំ
- ត្រូវចៀសវាងការផ្សព្វផ្សាយព័ត៌មានដែលញុះញង់ឱ្យមានការប្រកាន់ពូជសាសន៍ព័ណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា មតិ ឬនិន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬ ស្ថានភាពដទៃទៀត

- ត្រូវគោរពសិទ្ធិ និង សេរីភាពរស់នៅក្នុងជីវភាពឯកជនរបស់បុគ្គល
- ត្រូវគោរពឱ្យបានហ្មត់ចត់តាមក្បួនខ្នាតវេយ្យាករណ៍ខ្មែរក្នុងការសរសេរអត្ថបទ
- ហាមបោះពុម្ពផ្សព្វផ្សាយអត្ថបទ ឬ រូបភាពអាសអាភាស និងរូបភាពនៃអំពើហិង្សា
- ហាមរំលោភលើសិទ្ធិដើម្បីមានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់បុគ្គលម្នាក់ៗ

**៧- ខ្លឹមសារសង្ខេបនៃក្រមសីលធម៌សិល្បករ**

**(ប្រកាសលេខ ២២៥ ប្រក. ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១០)**

- ប្រកាន់ខ្ជាប់ខ្លួននូវគោលការណ៍សីលធម៌លើការប្រើសំណេរ ពាក្យសម្ដី កាយវិការ
- មានជំនាញជីវៈសិល្បៈណាមួយឱ្យបានច្បាស់លាស់
- សិក្សាស្រាវជ្រាវបង្កើតចំណេះដឹង និង ជំនាញ
- មានសុច្ឆន្ទៈក្នុងការផ្ទេរចំណេះដឹង និង ជំនាញ
- មានមនសិការវិជ្ជាជីវៈ (បម្រើប្រយោជន៍សាធារណៈ)
- ចៀសវាងសាងជម្លោះជាតិសាសន៍ និង ជំងឺ៣ (តួឯក ស្នេហា លាភសក្ការៈ)
- ចៀសវាងបន្ទាបបន្ថោកតម្លៃវិជ្ជាជីវៈសិល្បៈ
- ចៀសវាងសកម្មភាពធ្វើឱ្យអាប់ឱនដល់សិល្បករ
- ចៀសវាងយកអាជីពសិល្បៈទៅបម្រើអំពើខុសច្បាប់ ឬ អសីលធម៌
- ចៀសវាងប្រើអំណាច ឬ ឥទ្ធិពលសិល្បៈនាំឱ្យប៉ះពាល់ដល់កិត្តិយសនិងបទប្បញ្ញត្តិច្បាប់គតិយុត្ត។

**៨- ខ្លឹមសារសង្ខេបនៃក្រមសីលធម៌របស់អ្នកសម្ដែង**

**(ប្រកាសលេខ ២២៥ ប្រក. ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១០)**

- ប្រកាន់ខ្ជាប់មនសិការវិជ្ជាជីវៈ រក្សាភាពថ្លៃថ្នូរ
- គោរពវិន័យទាំង៣
- ពង្រឹង និង ពង្រីកសមត្ថភាព
- មិនត្រូវយកអារម្មណ៍ផ្ទាល់ខ្លួនឡូកឡំជាមួយការសម្ដែង
- មិនត្រូវលក់តម្លៃសិល្បៈដោយទឹកប្រាក់ឡើយ
- មិនត្រូវយកភាពល្បីរបស់ខ្លួនទៅគាបសង្កត់អ្នកដទៃដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន។

**៩- ខ្លឹមសារសង្ខេបនៃក្រមសីលធម៌របស់អ្នកបង្កើតស្នាដៃ**

**(ប្រកាសលេខ ២២៥ ប្រក. ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១០)**

- ប្រមូលផ្ដុំ ផ្ដោតលើពុទ្ធិ អប់រំ និងសិល្បវិទ្យា
- គាំទ្រគ្រប់សកម្មភាពអប់រំ ផ្សព្វផ្សាយ
- គ្រប់ស្នាដៃ ត្រូវមានប្រភព ឬ ឯកសារយោងច្បាស់លាស់
- ត្រូវតម្កល់ស្នាដៃទុកជាកេរដំណែលដល់អ្នកជំនាន់ក្រោយ

## **គន្ថនិទ្ទេស**


- ក្រមសីលធម៌មេធាវី គ. ស. ១៩៩៥
- ក្រមសីលធម៌សម្រាប់មន្ត្រីប្រតិបត្តិច្បាប់ គ. ស. ១៩៧៩
- កុក រស់ ៖ ***ពិធីការទូទៅ*** គ. ស. ២០១០
- ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល គ. ស. ១៩៩៤
- ច្បាប់ស្តីពីរបបសារព័ត៌មាន គ. ស. ១៩៩៥
- ប្រកាសស្តីពីក្រមសីលធម៌វិជ្ជាជីវៈសិល្បករ គ. ស. ២០១០
- ប៊ុន ហុន ៖ ***ក្រមសីលធម៌និងការទទួលខុសត្រូវចំណោះវិជ្ជាជីវៈមេធាវី*** គ. ស. ២០០៩
- ពុទ្ធសាសនបណ្ឌិត្យ ៖ **វចនានុក្រមខ្មែរ** គ. ស. ១៩៦៧
- ពេជ្រ ប៊ុនធិន ស៊ន សុឃន និងសិក ហេងឡុង ៖ ***ចំណេះដឹងអំពីមុខងារសាធារណៈ*** គ. ស. ២០១០
- អនុក្រឹត្យស្តីពីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន គ. ស. ២០០៨
- អនុក្រឹត្យស្តីពីក្រមសីលធម៌គ្រូពេទ្យ គ. ស. ២០០៣
- អនុក្រឹត្យស្តីពីក្រមសីលធម៌ចៅក្រម គ. ស. ២០០៧
- ឥន យឿន ៖ ***នីតិមុខងារសាធារណៈ*** គ. ស. ២០១៣